# មន្ត្រីបច្ចេកទេសចិញ្ចឹមសត្វ

**តើអ្នកមានចំណាប់អារម្មណ៍ធ្វើការ ដើម្បីគាំទ្រ និងលើកស្ទួយដល់សេដ្ឋកិច្ចយុវជនដែលបាត់បង់ឱកាស និងក្រុមគ្រួសារពួកគាត់ដែរឬទេ? តើអ្នកចង់ធ្វើការជាមួយក្រុមការងារ ដែលផ្តល់ការបណ្តុះបណ្តាលលើបច្ចេកទេសចិញ្ចឹមសត្វ និងការធ្វើកសិកម្មដែរឬទេ? បើមានចំណាប់អារម្មណ៍ អ្នកអាចមកចូលរួមជាមួយយើងបាន!**

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជិត ២៥០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្តល់នូវ សេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតវិធីសាស្ត្ររួម មួយចំនួន ដើម្បីគាំទ្រឲ្យកុមារត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ជានា ក្នុងការផ្តល់ការ បណ្តុះបណ្តាលជំនាញ ឬការងារ ទៅដល់យុវវ័យ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើង បានផ្តល់ការ បណ្តុះបណ្តាលដល់យុវជនលើជំនាញជាច្រើនដូចជ ចុងភៅ សេវាកម្ម គ្រឿងយន្ត សម្អាងកាយ ជាងកាត់សក់ ជាងផ្សា ផ្នែកអគ្គីសនី ផ្នែកកាត់ដេរ និងការបណ្តុះបណ្តាលដើម្បីបង្កើតចំណូលដល់អាណាព្យាបាល ។

បច្ចុប្បន្ន យើងកំពុងត្រូវការជ្រើសរើសអ្នកមានសមត្ថភាព សម្រាប់មុខតំណែង **មន្ត្រីបច្ចេកទេសចិញ្ចឹមសត្វ**។

**តើអ្នកត្រូវធ្វើអ្វី?**

ក្នុងតួនាទីជា **មន្ត្រីបច្ចេកទេសចិញ្ចឹមសត្វ** អ្នកត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសកសិកម្ម និងការចិញ្ចឹមសត្វ ទៅដល់យុវវ័យ និងក្រុមគ្រួសាររបស់ពួកគាត់ ដើម្បីឲ្យគាត់អាចបង្កើត និងគ្រប់គ្រងកសិដ្ឋានខ្នាតតូចដោយខ្លួនឯងបាន។

**អ្នកនឹងទទួលខុសត្រូវការងារសំខាន់ៗដូចខាងក្រោម៖**

- ធ្វើការវាយតម្លៃ និងជ្រើសរើសយុវវ័យ/គ្រួសារ ដើម្បីគាំទ្រពួកគេ ចិញ្ចឹមសត្វ និងធ្វើកសិកម្ម
- បណ្តុះបណ្តាលជំនាញ និងបច្ចេកទេសកសិកម្ម និងចិញ្ចឹមសត្វ
- ផ្គត់ផ្គង់សម្ភារៈពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ និងការធ្វើកសិកម្ម ឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា
- តាមដាន វាយតម្លៃ និងផ្តល់ការគាំទ្រជាប្រចាំទៅដល់យុវវ័យ/គ្រួសារគោលដៅ
- រៀបចំផែនការសកម្មភាព ផែនការថវិការ និងរបាយការណ៍លទ្ធផលការងារតាមការតម្រូវរបស់គម្រោង

**យើងត្រូវការអ្នកដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- អ្នកមានបរិញ្ញាបត្រផ្នែកពេទ្យសត្វ សញ្ញាប័ត្រប្រហាក់ប្រហែល ឬវគ្គបណ្តុះបណ្តាលពាក់ព័ន្ធផ្សេងៗ
- អ្នកមានបទពិសោធន៍ពាក់ព័ន្ធ០១ ទៅ០២ឆ្នាំជាមួយអង្គការ ស្ថាប័នផ្សេងៗ ឬ សហគមន៍ក្រីក្រ
- អ្នកជាបុគ្គលឯករាជ្យ អាចគ្រប់គ្រងការងារខ្លួនឯងបានយ៉ាងល្អប្រសើរ និងអាចធ្វើការជាមួយក្រុមប្រកបដោយប្រសិទ្ធិភាព
- អ្នកអាចប្រើប្រាស់កម្មវិធីកុំព្យូទ័រមួយចំនួន ដូចជា Word, Excel, Internet & Email
- អ្នកអាចអាន និងសរសេរភាសាអង់គ្លេសបានខ្លះ

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៏ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាស័យដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍ ។ ស្ត្រីត្រូវបានផ្តល់អទិភាពក្នុងការដាក់ពាក្យ ។

អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៏ការពារកុមារ។
ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨**។